**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃ ស្នួល ស្ថិតក្នុងភូមិសាស្ត្រឃុំ ពីរធ្នូ ស្រុក ស្នួល ខេត្ត ក្រចេះ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

មាត្រា១:

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃ ស្នួល លើផ្ទៃដីទំហំ ២.២៥១ (ពីរពាន់ពីររយហាសិប)ហិកតា ទៅជាតំបន់សហគមន៍ ស្ថិតនៅក្នុងឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ ។

មាត្រា២:

តំបន់សហគមន៍ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម:

| Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|
| A | ៦៨៨៨១៧ | ១៣៤២៨៨៥ | F | ៦៩៤១០៣ | ១៣៤០១០៨ |
| B | ៦៩០០០០ | ១៣៤២៤២៧ | G | ៦៩២៩៨៥ | ១៣៣៨៧៣១ |
| C | ៦៩៤០០០ | ១៣៤២៦៥៦ | H | ៦៨៩៩៧៩ | ១៣៣៨៧២៤ |
| D | ៦៩៦០០៥ | ១៣៤១៣៩៣ | I | ៦៨៨៨០៩ | ១៣៣៩៤៧១ |
| E | ៦៩៥៣២៩ | ១៣៣៩៧៣៣ | | | |

មាត្រា៣:

ការកំណត់តំបន់សហគមន៍ស្ថិតក្នុងភូមិសាស្ត្រឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ ជាតំបន់គ្រប់គ្រងបម្រើឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលកំពុងមានសកម្មភាពស្រាប់ រួមមាន: លំនៅឋាន ស្រែចម្ការ។ រាល់ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឲ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់សហគមន៍នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

មាត្រា៤:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៥:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ...០១... ខែ ...ធ្នូ...... ឆ្នាំ ២០១០.

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ



| ID | N | X | Y |
|---|---|---|---|
| 1 | A | 688817 | 1342885 |
| 2 | B | 690000 | 1342427 |
| 3 | C | 694000 | 1342656 |
| 4 | D | 696005 | 1341393 |
| 5 | E | 695329 | 1339733 |
| 6 | F | 694103 | 1340108 |
| 7 | G | 692985 | 1338731 |
| 8 | H | 689979 | 1338724 |
| 9 | I | 688809 | 1339471 |